# សិក្ខាសាលាពិគ្រោះយោបល់ស្តីពី ការផ្តល់ធាតុចូលរបស់អង្គការសង្គមស៊ីវិលលើ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ) ២០២៤-២០២៨

**ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៣**

**ទីកន្លែង៖ មជ្ឈមណ្ឌលឌីខេ**

**(ផ្លូវលេខ ៣៣០ ជិតសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង)**

## សេចក្តីផ្តើម

កន្លងមករាជរដ្ឋាភិបាលកម្ពុជា តែងតែផ្តល់ឱកាសដល់អង្គការសង្គមស៊ីវិលផ្តល់ធាតុចូលក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ជាក់ស្តែងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ ត្រូវបានផ្តល់ធាតុចូលដោយអង្គការសង្គមស៊ីវិល នៅចុងឆ្នាំ២០១៨ និងនៅក្នុងការត្រួតពិនិត្យពាក់កណ្តាលអាណត្តិឆ្នាំ២០២១ ផងដែរ។ អង្គការសង្គមស៊ីវិលបានចូលរួមយ៉ាងសកម្មក្នុងការធ្វើការជាមួយអ្នកបង្កើតគោលនយោបាយឱ្យទទួលខុសត្រូវលើការប្តេជ្ញាចិត្តប្រកបដោយតម្លាភាព និងមានលក្ខណៈប្រកបដោយបរិយាបន្នក្នុងដំណើរការត្រួតពិនិត្យ និងវាយតម្លៃ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ ត្រូវបានរៀបចំឡើងសម្រាប់ការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ក្រោមការសម្របសម្រួលរបស់ក្រសួងផែនការ និងកិច្ចសហការពីតួអង្គអភិវឌ្ឍន៍ទាំងអស់។

កាលពីថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ កន្លងទៅ ក្រសួងផែនការបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយណែនាំពីការរៀបចំធាតុចូលសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០២៤-២០២៨។ បន្ទាប់ពីសិក្ខាសាលាថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ **អង្គការសង្គមស៊ីវិលមានពេលវេលារហូតដល់ថ្ងៃទី ៧ មេសា ២០២៣ សម្រាប់រៀបចំធាតុចូលផ្តល់ទៅក្រសួងសាមុីនីមួយៗ និងត្រឹមថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២៣ សម្រាប់រៀបចំធាតុចូលផ្តល់ទៅក្រសួងផែនការ** ។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០២៤-២០២៨ គឺជាឧបករណ៍ដ៏សំខាន់តែមួយគត់សម្រាប់អនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីការអនុវត្តឆ្ពោះទៅសម្រេចបានចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០ និងជាផែនការសម្រាប់អនុវត្តធ្វើឱ្យសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ឆ្នាំ២០៣០ និងរួមចំណែកធ្វើឱ្យសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពសាកល និងក៏ជាឧបករណ៍ដ៏សំខាន់សម្រាប់ការអនុវត្តដើម្បីនាំកម្ពុជាចាកចេញពីប្រទេសដែលមានការអភិវឌ្ឍតិចតួច។

ហេតុដូចនេះហើយ អង្គការ គ.ស.ក រួមជាមួយសមាជិករបស់ខ្លួនចំនួន១៩២ អង្គការក្នុងស្រុក និងបរទេស និងបណ្តាញអង្គការតាមខេត្ត ចំនួន១៦ខេត្ត នឹងរៀបចំឱ្យមានសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការផ្តល់ធាតុចូល

របស់អង្គការសង្គមស៊ីវិលលើផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ) ២០២៤-២០២៨ រយៈពេល ១ថ្ងៃពេញ នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៣។ សិក្ខាសាលានេះ នឹងមានអ្នកចូលរួមសរុបប្រមាណ ៧០នាក់។

## គោលបំណង

- ផ្តល់ព័ត៌មានពីដំណើរការនៃការរៀបចំផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ២០២៤-២០២៨ ដល់អង្គការសង្គមស៊ីវិលដែលជាសមាជិករបស់អង្គការ គ.ស.ក បណ្តាញអង្គការថ្នាក់ខេត្ត និងអង្គការដៃគូរមួយចំនួនផ្សេងទោត។
- បង្ហាញពីទម្រង់ និងខ្លឹមសារនៃធាតុចូលដែលត្រូវរៀបចំដោយអង្គការសង្គមស៊ីវិលសម្រាប់ផ្តល់ជូនក្រសួងផែនការ។
- ធ្វើការពិភាក្សា និងប្រមូលធាតុចូលស្តីពីផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ២០២៤-២០២៨ ផ្តល់ជូនក្រសួងពាក់ព័ន្ធនីមួយៗ និងក្រសួងផែនការ។

## របៀបវារៈព្រាង

| ម៉ោង | សកម្មភាព | អ្នកសម្របសម្រួល |
|---|---|---|
| ៨:០០-៨:៣០ | ចុះឈ្មោះអ្នកចូលរួម | ក្រុមការងារ អង្គការ គ.ស.ក |
| ៨:៣០-៨:៤៥ | គោរពភ្លេងជាតិគោលបំណង និងរបៀបវារៈសិក្ខាសាលា | លោកស្រី **ប្រាក់ កែវគន្ធា** អ្នកឯកទេសច្បាប់ |
| ៨:៤៥-៨:៥៥ | មតិស្វាគមន៍ដោយ **លោក ច័ន្ទ ភក្តី** នាយកប្រតិបត្តិស្តីទីនៃអង្គការ គ.ស.ក | លោក **ច័ន្ទ ភក្តី** នាយកប្រតិបត្តិស្តីទីនៃអង្គការ គ.ស.ក |
| ៨:៥៥-៩:០៥ | មតិគន្លឹះដោយតំណាងកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) ប្រចាំនៅកម្ពុជា | តំណាងកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) ប្រចាំនៅកម្ពុជា **(បញ្ជាក់ជូនតាមក្រោយ)** |
| ៩:០៥-៩:៣០ | សន្ទរកថាស្វាគមន៍ និងបើកកម្មវិធី ដោយតំណាងក្រសួងផែនការ | តំណាងក្រសួងផែនការ **(បញ្ជាក់ជូនតាមក្រោយ)** |
| ៩:៣០-៩:៥០ | សម្រាកអាហារសម្រន់ | |
| ៩:៥០-១១:០០ | **បទបង្ហាញ៖** ដំណើរការ ទម្រង់ និងខ្លឹមសារនៃធាតុចូលដែលត្រូវរៀបចំដោយអង្គការសង្គមស៊ីវិលសម្រាប់ផ្តល់ជូនក្រសួងផែនការ | មន្រ្តីបច្ចេកទេសពីក្រសួងផែនការ **(បញ្ជាក់ជូនតាមក្រោយ)** |
| ១១:០០-១២:០០ | **ការណែនាំពីការពិភាក្សាជាក្រុម៖** ដំណើរការ និងកិច្ចពិភាក្សា | ក្រុមការងារអង្គការ គ.ស.ក |



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street. 476,
Toul Tompoung 1, Chamkamorn
P.O. Box 855 Phnom Penh,
Cambodia

| | | |
|---|---|---|
| | **ពិភាក្សាក្រុមផ្តល់ធាតុចូល៖**<br>1. ការបង្កើនល្បឿនកែទម្រង់អភិបាលកិច្ចល្អ<br>2. បរិស្ថានគ្របដណ្តប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រទាំងមូល<br>3. ការអភិវឌ្ឍធនធានមនុស្ស<br>4. ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការបង្កើនការប្រកួតប្រជែង<br>5. ការអភិវឌ្ឍវិស័យឯកជន និងការងារ<br>6. ការអភិវឌ្ឍប្រកបដោយភាពធន់ ចីរភាព និងបរិយាបន្ន<br>7. ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថល | |
| ១២:០០-១៣:៣០ | សម្រាកអាហារថ្ងៃត្រង់ | |
| ១៣:៣០-៣:០០ | បន្តពិភាក្សាក្រុមផ្តល់ធាតុចូល | ក្រុមការងារអង្គការ គ.ស.ក |
| ៣:០០-៣:២០ | សម្រាកអាហារសម្រន់ | |
| ៣:២០-៤:៣០ | បន្តពិភាក្សាក្រុមផ្តល់ធាតុចូល<br>បង្ហាញលទ្ធផលពិភាក្សាក្រុម | ក្រុមការងារអង្គការ គ.ស.ក |
| ៤:៣០-៤:៤៥ | បូកសរុប និងបិទកម្មវិធីដោយ លោកស្រី លុយ ធារី ប្រធានកម្មវិធីអង្គការ គ.ស.ក | លោកស្រី **លុយ ធារី** ប្រធានកម្មវិធីអង្គការ គ.ស.ក |

**សម្គាល់៖** អង្គការ គ.ស.ក សូមរក្សាសិទ្ធិក្នុងការកែប្រែកម្មវិធី ក្នុងករណីចាំបាច់។

កម្មវិធីនេះ មានបកប្រែជាភាសាអង់គ្លេស-ខ្មែរ។ សូមជម្រាបជូនជ្រាបថា៖ សកម្មភាព និងខ្លឹមសារសំខាន់ៗមួយចំនួនរបស់អ្នកចូលរួម នឹងត្រូវបានដកស្រង់ និងចែករំលែកតាមប្រព័ន្ធផ្សព្វផ្សាយដូចជា គេហទំព័រ និងបណ្តាញព័ត៌មានសង្គម។ http://www.ccc-cambodia.org/en/resources/event-archives www.facebook.com/CCCsince1990 www.youtube.com/CCCambodia



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street. 476,
Toul Tompoung 1, Chamkamorn
P.O. Box 855 Phnom Penh,
Cambodia